# វេទិកាសិក្សាលើកទី ២

## ស្តីពី

# ការឆ្លុះបញ្ចាំងអំពីការប្រតិបត្តិរបស់អង្គការសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងនិរន្តរភាព

**ថ្ងៃទី ១២-១៣ ខែធ្នូ ឆ្នាំ២០១៧ នៅសណ្ឋាគារកែបឃេ ខេត្តកែប**

## លទ្ធផលលម្អិតនៃកិច្ចពិភាក្សាតាមក្រុមលើទីផ្សារ ការធ្វើផែនទីធនធាន និងការបង្កើតសមាគមសម្រាប់អង្គការសហគមន៍មូលដ្ឋាន

### ក្រុម ១៖ ក្រុមសហគមន៍នេសាទទឹក

**១. តើលោកអ្នកសង្កេតឃើញថាសហគមន៍របស់លោកអ្នកមានធនធានអ្វីខ្លះដែលអាចធ្វើអាជីវកម្មបាន?**

- សហគមន៍មានធនធានសម្រាប់ប្រកបអាជីវកម្មមានដូចជា ជីវចំរុះមានបង្គា ក្តាម ខ្យង ត្រី ងាវគ្រែងកូនកោងកាង មានផ្ទះស្នាក់នៅ ទូកដឹកភ្ញៀវ ទូកនេសាទ ឧបករណ៍នេសាទលក្ខណៈគ្រួសារ ជាងឈើ ម៉ូតូឌុប។

**២. តើធនធានទាំងនោះជាតម្រូវការទីផ្សារដែរឬទេ? តើគួរកែច្នៃរបៀបណាដើម្បីអោយធនធានទាំងនោះកាន់តែមានទីផ្សារ?**

ធនធានទាំងនោះ គឺជាតម្រូវការទីផ្សារចាំបាច់បំផុតនៅក្នុងសហគមន៍។ យើងអាចកែច្នៃធ្វើជាបង្គាក្រៀម គឺ ទឹកត្រី ផ្អកត្រី យាវហោ ផ្អកគ្រែង ផ្អកបង្គា ត្រីងៀត មាំ ផ្អកខ្យងភី ផ្អកខ្យងថ្មី ចាវត្រី អ៊ីយស្ងួរ ត្រីចំហុយ ។ល។

**៣. តើប្រជាពលរដ្ឋនៅសហគមន៍របស់លោកអ្នកមានជំនាញក្នុងការកែច្នៃធនធានទាំងនោះដើម្បីធ្វើអាជីវកម្មដែរឬទេ? បើមានគាត់បានធ្វើអ្វី? បើមិនមានតើគួរធ្វើអ្វី? តើមានអង្គការ ឬវិស័យឯកជនណាដែលអាចគាំទ្រ និងផ្តល់ជំនាញទាំងនោះ?**

ប្រជាពលរដ្ឋមានជំនាញកែច្នៃជីវចំរុះគ្រប់ប្រភេទ

**៤. តើលោកអ្នកដឹងថាមានសហគមន៍ណាដែលមានធនធានដូច ឬប្រហាក់ប្រហែលធនធានរបស់លោកអ្នកដែរឬទេ? បើមានតើនៅតំបន់ណាខ្លះ?**

សហគមន៍ដែលមានធនធានប្រហាក់ប្រហែលគ្នា កោះកុង ព្រះសីហនុ កំពត និងកែប

**៥. តើលោកអ្នកមានទំនាក់ទំនង ឬចងក្រងបណ្តាញជាមួយពួកគាត់យ៉ាងដូចម្តេច? បើមិនទាន់មានតើគួរធ្វើដូចម្តេច?**

សហគមន៍បានចងក្រងបណ្តាញសហគមន៍មួយជាមួយសហគមន៍មួយទៀត ដើម្បីរកដំណោះស្រាយរួម និងផ្តល់បទពិសោធន៍ពីសហគមន៍មួយទៅសហគមន៍មួយ។

**៦. តើលោកអ្នកមានសំណូមពរអ្វីខ្លះសម្រាប់អង្គការសហការទាំងអស់?**

សហគមន៍យើងសូមសំណូមពរអង្គការស៊ី ស៊ី និងអង្គការដៃគូទាំងអស់អោយជួយ គាំទ្រ វគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពដល់សហគមន៍។

- ផ្នែកវិស័យទេសចរណ៍៖ គាំទ្រល្បាត ធានាគារក្តាម ក្រុមចិញ្ចឹមត្រី ក្រុមកែច្នៃជីវចម្រុះ
- ទៅទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍តាមបណ្តាខេត្ត

## ក្រុម ២៖ ក្រុមសហគមន៍នេសាទទី២

**១. តើលោកអ្នកសង្កេតឃើញថាសហគមន៍របស់លោកអ្នកមានធនធានអ្វីខ្លះដែលអាចធ្វើអាជីវកម្មបាន?**

នៅក្នុងសហគមន៍នេសាទមានធនធានធម្មជាតិ ដូចជា

- ព្រៃកោងកាង មានតំបន់អភិរក្សជីវចម្រុះ
- ផលនេសាទដូចជាក្តាម ងាវ ខ្ចង បង្គា មឹក ត្រី ។ល។

**២. តើធនធានទាំងនោះជាតម្រូវការទីផ្សារដែរឬទេ? តើគួរកែច្នៃរបៀបណាដើម្បីអោយធនធានទាំងនោះកាន់តែមានទីផ្សារ?**

ធនធានទាំងនោះគឺជាតម្រូវការទីផ្សារយ៉ាងសំខាន់ កែច្នៃទៅជាបង្គាក្រៀម ផ្អក បង្គារ ផ្អកត្រី ត្រីងៀត ធ្វើដោយមានការវិចខ្ចប់ និងអនាម័យបានល្អ។

**៣. តើប្រជាពលរដ្ឋនៅសហគមន៍របស់លោកអ្នកមានជំនាញក្នុងការកែច្នៃធនធានទាំងនោះដើម្បីធ្វើអាជីវកម្មដែរឬទេ? បើមានគាត់បានធ្វើអ្វី? បើមិនមានតើគួរធ្វើអ្វី? តើមានអង្គការ ឬវិស័យឯកជនណាដែលអាចគាំទ្រ និងផ្តល់ជំនាញទាំងនោះ?**

ប្រជាពលរដ្ឋនៅក្នុងសហគមន៍មានជំនាញកែច្នៃ វត្ថុអនុស្សាវរីយ៍ ដូចជាសំបកខ្ចងធ្វើជារូបសត្វ ជាផ្កា។ល។

**៤. តើលោកអ្នកដឹងថាមានសហគមន៍ណាដែលមានធនធានដូច ឬប្រហាក់ប្រហែលធនធានរបស់លោកអ្នកដែរឬទេ? បើមានតើនៅតំបន់ណាខ្លះ?**

សហគមន៍ដែលមានធនធានប្រហាក់ប្រហែលគ្នា ដូចជាកែប កំពត កំពង់សោម និងកោះកុង។

**៥. តើលោកអ្នកមានទំនាក់ទំនង ឬចងក្រងបណ្តាញជាមួយពួកគាត់យ៉ាងដូចម្តេច? បើមិនទាន់មានតើគួរធ្វើដូចម្តេច?**

សហគមន៍បានទំនាក់ទំនង និងចងបណ្តាញតាមរយៈអង្គការ និងជំនាញដែលពាក់ព័ន្ធ។



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

**៦. តើលោកអ្នកមានសំណូមពរអ្វីខ្លះសម្រាប់អង្គការសហការទាំងអស់?**

សំណូមពរអោយអង្គការជួយដូចជា

- ទុកសម្រាប់ចុះល្បាត វិទ្យុទាក់ទង អាវពោង ឯកសណ្ឋាន ថវិកា និងទស្សនកិច្ចសិក្សាតាមសហគមន៍ដែលដំណើរការបានជោគជ័យ។

## ក្រុម ៣៖ ក្រុមសន្សំ និងធនាគារនៅខេត្តកណ្តាល

**១. តើលោកអ្នកសង្កេតឃើញថាសហគមន៍របស់លោកអ្នកមានធនធានអ្វីខ្លះដែលអាចធ្វើអាជីវកម្មបាន?**

សហគមន៍យើងខ្ញុំមានធនធានដូចជា សន្សំប្រាក់ ធនាគារគោ ធនាគារស្រូវ មាន់ ទា ត្រី បន្លែធម្មជាតិ រោងតុ ផ្សារសហគមន៍ រោងជីកំប៉ុស ស្រែរួម បន្លែរួម។

**២. តើធនធានទាំងនោះជាតម្រូវការទីផ្សារដែរឬទេ? តើគួរកែច្នៃរបៀបណាដើម្បីអោយធនធានទាំងនោះកាន់តែមានទីផ្សារ?**

ធនធានទាំងនោះជាតម្រូវការទីផ្សារ ដោយកែច្នៃធនធានទាំងនោះ អោយមានគុណភាពដោយប្រើជីធម្មជាតិ ។

**៣. តើប្រជាពលរដ្ឋនៅសហគមន៍របស់លោកអ្នកមានជំនាញក្នុងការកែច្នៃធនធានទាំងនោះដើម្បីធ្វើអាជីវកម្មដែរឬទេ? បើមានគាត់បានធ្វើអ្វី? បើមិនមានតើគួរធ្វើអ្វី? តើមានអង្គការ ឬវិស័យឯកជនណាដែលអាចគាំទ្រ និងផ្តល់ជំនាញទាំងនោះ?**

ប្រជាពលរដ្ឋនៅក្នុងសហគមន៍មានជំនាញកែច្នៃ ធនធានទាំងនោះ នៅមានកម្រិត

- ចិញ្ចឹមទា មាន់ បន្លែ គោ ស្រូវ ។ល។
- ខ្វះការយល់ដឹង និងសម្ភារៈ
- សហគមន៍យើងមានអង្គការ KCD, OREDA, CWDCC

**៤. តើលោកអ្នកដឹងថាមានសហគមន៍ណាដែលមានធនធានដូច ឬប្រហាក់ប្រហែលធនធានរបស់លោកអ្នកដែរឬទេ? បើមានតើនៅតំបន់ណាខ្លះ?**

សហគមន៍ដែលមានធនធាន ប្រហាក់ប្រហែល

- សហគមន៍ស្ពាងតាំយូរ
- សហគមន៍កសិកម្ម ឈូក
- 

**៥. តើលោកអ្នកមានទំនាក់ទំនង ឬចងក្រងបណ្តាញជាមួយពួកគាត់យ៉ាងដូចម្តេច? បើមិនទាន់មានតើគួរធ្វើដូចម្តេច?**

បានទំនាក់ទំនងតាមរយៈសិក្ខាសាលា ទស្សនកិច្ចសិក្សា



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,Cambodia

Accountability គណនេយ្យភាព
GPP 25/08/2015 24/08/2018
Symbol of Trust

**៦. តើលោកអ្នកមានសំណូមពរអ្វីខ្លះសម្រាប់អង្គការសហការទាំងអស់?**

- យើងត្រូវចងក្រងជាប្រព័ន្ធ ឬបណ្តាញ
- ជួយរកទីផ្សារ
- មានវគ្គបណ្តុះបណ្តាល ជំនាញទីផ្សា បច្ចេកទេសកសិកម្ម ជំនាញកែច្នៃផលិតផលកសិកម្ម របៀបសរសេរគម្រោងស្នើសុំ។ល។
- ទស្សនកិច្ចសិក្សាចែករំលែកបទពិសោធន៍ពីសហគមន៍មួយទៅសហគមន៍មួយ

## ក្រុម ៨៖ សហគមន៍ តំបន់ការពារព្រៃឈើ

**១. តើលោកអ្នកសង្កេតឃើញថាសហគមន៍របស់លោកអ្នកមានធនធានអ្វីខ្លះដែលអាចធ្វើអាជីវកម្មបាន?**

សហគមន៍យើងខ្ញុំមានធនធានដូចជា តំបន់ទឹកធ្លាក់ ឫស្សី ផ្តៅ ជ័រ ផ្សិត ទឹកឃ្មុំ រុក្ខជាតិឱសថ បន្លែព្រៃ ក្តាមបង្កាងារ ត្រីទឹកសាប និងទឹកប្រៃ តំបន់អេកូរទេសចរណ៍ (ព្រៃកោងកាង ......... ។ល។)

**២. តើធនធានទាំងនោះជាតម្រូវការទីផ្សារដែរឬទេ? តើគួរកែច្នៃរបៀបណាដើម្បីអោយធនធានទាំងនោះកាន់តែមានទីផ្សារ?**

ធនធានខាងលើទាំងអស់ជាតម្រូវការទីផ្សារ បង្កើតបឹងកាឡូរ គ្រឿងសង្ហារិម ឱសថបុរាណ កែច្នៃជាអាហារក្រៀម។

**៣. តើប្រជាពលរដ្ឋនៅសហគមន៍របស់លោកអ្នកមានជំនាញក្នុងការកែច្នៃធនធានទាំងនោះដើម្បីធ្វើអាជីវកម្មដែរឬទេ? បើមានគាត់បានធ្វើអ្វី? បើមិនមានតើគួរធ្វើអ្វី? តើមានអង្គការ ឬវិស័យឯកជនណាដែលអាចគាំទ្រ និងផ្តល់ជំនាញទាំងនោះ?**

ប្រជាពលរដ្ឋនៅក្នុងសហគមន៍មិនទាន់មានជំនាញគ្រប់គ្រាន់ក្នុងការកែច្នៃ៖ ទឹកឃ្មុំ បង្គាក្រៀម ក្តាមប្រៃ អនុផលព្រៃឈើ។

**៤. តើលោកអ្នកដឹងថាមានសហគមន៍ណាដែលមានធនធានដូច ឬប្រហាក់ប្រហែលធនធានរបស់លោកអ្នកដែរឬទេ? បើមានតើនៅតំបន់ណាខ្លះ?**

សហគមន៍ដែលមានធនធាន ប្រហាក់ប្រហែលគឺសហគមន៍តំបន់ការពារចំការក្រោមប្រាំង នាពិសី ជ្រោយស្វាយ ស្រុកស្រែអំបិលកោះកុង ត្រពាំងសង្កែ ស្រុកទឹកឈូ កោះតូច សហគមន៍ព្រៃឈើចំបក់ កំពង់ស្ពឺ។

**៥. តើលោកអ្នកមានទំនាក់ទំនង ឬចងក្រងបណ្តាញជាមួយពួកគាត់យ៉ាងដូចម្តេច? បើមិនទាន់មានតើគួរធ្វើដូចម្តេច?**

មានទំនាក់ទំនង តែគ្មានបណ្តាញ និងស្វែងរកតាមអង្គការដៃគូសម្រាប់វគ្គបណ្តុះបណ្តាល។

**៦. តើលោកអ្នកមានសំណូមពរអ្វីខ្លះសម្រាប់អង្គការសហការទាំងអស់?**

សំណូមអោយអង្គការ CCC និងអង្គការផ្សេងៗ គាំទ្រដល់សហគមន៍ ជំនាញ និងសេវាទំនាក់ទំនងដៃគូ។

រៀបចំដោយ៖ កញ្ញា កៅ ពៅលក្ខិណា
អ្នកឯកទេសផ្នែកអង្គការសហគមន៍មូលដ្ឋាន
លេខទូរស័ព្ទ៖ ០១២ ៨៧២ ០៥៣
អ៊ីមែល៖ peouleakhena.kao@ccc-cambodia.org
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា